រដ្ឋសភា
ចូល
លេខ ...
ថ្ងៃទី ... ឆ្នាំ២០១៤ ម៉ោង ...
បញ្ជូនទៅ ...

# ព្រះរាជក្រម

នស/រកម/១២១៤/០២៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៤ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ក្រសួងព្រះបរមរាជវាំង

# ច្បាប់

# ស្ដីពី

# ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង

# ឆ្នាំ ២០១៥

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១
## ថវិកាថ្នាក់ជាតិ

### មាត្រា ១.-

ត្រូវបានអនុញ្ញាតសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥ ឲ្យប្រមូលចំណូលបង់ចូលថវិកាថ្នាក់ជាតិ នូវពន្ធដារ វិភាគទាន អាករ ផលទុន និងចំណូលនានា ព្រមទាំងធ្វើឲ្យសម្រេចនូវឧបត្ថម្ភកធនវិនិយោគ និងការខ្ចីតាមមាតិកាថវិកា ដូចមានចែងក្នុងតារាង "ក" ដែលភ្ជាប់មកជាមួយច្បាប់នេះ ក្នុងទឹកប្រាក់សរុបចំនួន ១៥ ១៣៥ ២៣០ លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណូលចរន្ត...........................................................១១ ០១៤ ៦៤៤ លានរៀល
- ចំណូលមូលធន.........................................................៤ ១២០ ៥៨៦ លានរៀល
  + ចំណូលមូលធនក្នុងប្រទេស.....................................១៣៣ ៥៨៦ លានរៀល
  + ចំណូលមូលធនក្រៅប្រទេស.....................................៣ ៩៨៧ ០០០ លានរៀល
    - មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ
      .........................................................................៣០០ ០០០ លានរៀល
    - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស
      .......................................................................៣ ៦៨៧ ០០០ លានរៀល

### មាត្រា ២.-

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥ ត្រូវបានកំណត់ស្មើនឹង ១៥ ០៣៥ ២២៩ លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណាយចរន្ត..........................................................៩ ២៧៥ ១៦១ លានរៀល
- ចំណាយមូលធន........................................................៥ ៧៦០ ០៦៨ លានរៀល

  ក-វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

  ...........................................................................១ ៦៣៦ ៥០០ លានរៀល

  - ដោយថវិកាថ្នាក់ជាតិ.........................................១ ៣៣៦ ៥០០ លានរៀល
    - គម្រោងវិនិយោគផ្ទាល់.........................១ ០១៩ ៧០០ លានរៀល

• បដិភាគក្នុងការអនុវត្តគម្រោងហិរញ្ញប្បទានក្រៅប្រទេស

.......................................................៣១៦ ៨០០ លានរៀល

- ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ

.......................................................៣០០ ០០០ លានរៀល

ខ-វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

.......................................................៣ ៦៨៧ ០០០ លានរៀល

គ- ការទូទាត់ការខ្ចី.......................................................៤៣៦ ៥៦៨ លានរៀល

**មាត្រា ៣.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយចរន្តថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥ ត្រូវបានកំណត់ស្មើនឹង ៩ ២៧៥ ១៦១ លានរៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និងទៅតាមប្រភេទចំណាយ ដូចមានចែងក្នុងតារាង "ខ" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ៤.-**

ចំនួនទឹកប្រាក់នៃឥណទានចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសសម្រាប់ការគ្រប់គ្រងពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៧ ត្រូវបានកំណត់ស្មើនឹង ១៥ ៣៤៧ ៩១២ លានរៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ តាមគម្រោង និងតាមឆ្នាំ ដូចមានចែងក្នុងតារាង "គ១" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ៥.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានភ្ជាប់សន្យា និងឥណទានទូទាត់សម្រាប់ចំណាយមូលធនថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥ ត្រូវបានកំណត់ដូចខាងក្រោម ៖

• ឥណទានភ្ជាប់សន្យា.......................................................៥ ៧៦០ ០៦៨ លានរៀល
• ឥណទានទូទាត់.......................................................៥ ៧៦០ ០៦៨ លានរៀល

ROYAUME DU CAMBODGE * LE MINISTÈRE DU PALAIS ROYAL *

ឥណទាននេះត្រូវបានបែងចែកដូចតទៅ៖

ក. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

- ឥណទានភ្ជាប់សន្យា......................................១ ៦៣៦ ៥០០ លានរៀល
- ឥណទានទូទាត់..............................................១ ៦៣៦ ៥០០ លានរៀល

ខ. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

- ឥណទានភ្ជាប់សន្យា......................................៣ ៦៨៧ ០០០ លានរៀល
- ឥណទានទូទាត់..............................................៣ ៦៨៧ ០០០ លានរៀល

គ. ការទូទាត់ការខ្ចី

- ឥណទានភ្ជាប់សន្យា..........................................៤៣៦ ៥៦៨ លានរៀល
- ឥណទានទូទាត់..................................................៤៣៦ ៥៦៨ លានរៀល

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ ដូចមានចែងក្នុងតារាង "គ២" និង "ឃ" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ៦.-**

គុល្យភាពនៃថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥ ដែលបានរៀបចំនៅក្នុងតារាង "ក" ស្តីពីចំណូលថវិកាថ្នាក់ជាតិ និងតារាង "ខ" ស្តីពីចំណាយថវិកាថ្នាក់ជាតិ ត្រូវបានបង្ហាញនៅក្នុងតារាងកិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិដូចខាងក្រោម ៖

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL